# បុញ្ញរាសី

**នៅក្នុងវចនានុក្រម សម្ដេចព្រះសង្ឃរាជ ជួន ណាត**

*ពាក្យថា* **បុញ្ញ** *ប្រែថា គុណជាតជាគ្រឿងជម្រះសន្ដានចិត្ត ឬដែលកើតពីចិត្តជ្រះថ្លា គឺបុណ្យ កុសល អំពើល្អ ។*

**រាសី** *ប្រែថា គំនរ ពំនូក ពួក កង ប្រជុំ ។*

**បុញ្ញរាសី** *ប្រែថា គំនរបុណ្យ ( បុណ្យដែលមានច្រើនក្រាស់ក្នុងសន្ដានចិត្ត ) ។ (* **ទំព័រ ៥៧៤-៥** *)*

## ទក្ខិណាវិភង្គសូត្រ

## ( បិដក ២៨ ទំព័រ ២១៤ - ២៣០ )

*[ ១៨១ ] ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងនិគ្រោធារាម ជិតក្រុងកបិលព័ស្ដុ ក្នុងដែនសក្កៈ ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី នាំយកសំពត់ថ្មី ១ គូ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះនាងមហាបជាបតិគោតមី គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មី ១ គូនេះ ខ្ញុំម្ចាស់វៃខ្លួនឯង ត្បាញខ្លួនឯង ផ្ចង់ចំពោះព្រះមានព្រះភាគ*

បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ អាស្រ័យនូវសេចក្តីអនុគ្រោះចំពោះខ្ញុំម្ចាស់ ទទួលយកនូវសំពត់នោះ ។

[ ១៨២ ] កាលបើព្រះនាងមហាបជាបតិគោតមី ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏មានព្រះបន្ទូលនឹងព្រះនាងមហាបជាបតិគោតមីដូច្នេះថា បពិត្រព្រះនាងគោតមី សូមព្រះនាងប្រគេន ( សំពត់នេះ ) ចំពោះសង្ឃវិញចុះ កាលបើព្រះនាងប្រគេនសំពត់នេះ ចំពោះសង្ឃហើយ តថាគតឈ្មោះថា ព្រះនាងបានបូជាហើយផង ទាំងសង្ឃក៏ឈ្មោះថា ព្រះនាងបានបូជាហើយដែរ ។ ព្រះនាងមហាបជាបតិគោតមី ក្រាបបង្គំទូលអង្វរព្រះមានព្រះភាគ អស់វារៈ ២ ដង ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មី ១ គូនេះ ខ្ញុំម្ចាស់រវៃខ្លួនឯង ត្បាញខ្លួនឯង ឧទ្ទិសចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ អាស្រ័យនូវសេចក្តីអនុគ្រោះចំពោះខ្ញុំម្ចាស់ ទទួលយកនូវសំពត់នោះ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូល នឹងព្រះនាងមហាបជាបតិគោតមី អស់វារៈ ២ ដង ដូច្នេះថា បពិត្រព្រះនាងគោតមី សូមព្រះនាងប្រគេនសង្ឃវិញចុះ កាលបើព្រះនាងប្រគេនសង្ឃហើយ តថាគតក៏ឈ្មោះថា ព្រះនាងបានបូជាហើយផង ទាំងសង្ឃក៏ឈ្មោះថា ព្រះនាងបានបូជាហើយដែរ ។ ព្រះនាងមហាបជា-

បតិគោតមី ក្រាបបង្គំទូលព្រះមានព្រះភាគ អស់វារៈ ៣ ដង ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មី ១ គូនេះ ខ្ញុំម្ចាស់វៃខ្លួនឯង ត្បាញខ្លួនឯង ឧទ្ទិសចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ អាស្រ័យនូវសេចក្តីអនុគ្រោះចំពោះខ្ញុំម្ចាស់ ទទួលយកនូវសំពត់នោះ ។ ព្រះមាន-ព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងព្រះនាងមហាបជាបតិគោតមី អស់វារៈ ៣ ដង ដូច្នេះថា បពិត្រព្រះនាងគោតមី សូមព្រះនាងប្រគេនសង្ឃវិញចុះ កាលបើព្រះនាងប្រគេនសង្ឃហើយ តថាគតក៏ឈ្មោះថា ព្រះនាងបានបូជាហើយផង ទាំងសង្ឃក៏ឈ្មោះថាព្រះនាងបានបូជាហើយដែរ ។

[ ១៨៣ ] កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលអង្វរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមាន-ព្រះភាគ ទ្រង់ទទួលសំពត់ថ្មី ១ គូ របស់ព្រះនាងមហាបជាបតិ-គោតមី បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមីជាអ្នកមានឧបការៈច្រើន ជាព្រះមាតុច្ឆារបស់ព្រះមានព្រះភាគជាអ្នកថែរក្សា អ្នកចិញ្ចឹម អ្នកថ្វាយទឹកក្សីរ កាលព្រះមាតាបង្កើតព្រះមានព្រះភាគ ទ្រង់ទិវង្គតទៅ នាងបានបំបៅទឹកដោះ បពិត្រ

ព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគ ក៏មានឧបការៈច្រើន ដល់ព្រះនាងមហាបជាបតិគោតមីដែរ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះនាងមហាបជាបតិគោតមី អាស្រ័យព្រះមានព្រះភាគ ទើបបានដល់នូវព្រះពុទ្ធជាទីពឹង បានដល់នូវព្រះធម៌ជាទីពឹង បាន ដល់នូវព្រះសង្ឃជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហា-បជាបតិគោតមី អាស្រ័យព្រះមានព្រះភាគ ទើបជាអ្នកវៀរចាក ការសម្លាប់សត្វ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ វៀរចាកការនិយាយ កុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវ ទឹកស្រវឹង គឺសុរា និងមេរ័យ បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាង មហាបជាបតិគោតមី អាស្រ័យនូវព្រះមានព្រះភាគ ទើបប្រកប ដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តី ជ្រះថ្លាមិនកម្រើក ក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លាមិន កម្រើក ក្នុងព្រះសង្ឃ ប្រកបដោយសីលទាំងឡាយ ដែលជាទី ត្រេកអរនៃព្រះអរិយបុគ្គល បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាង មហាបជាបតិគោតមី អាស្រ័យនូវព្រះមានព្រះភាគ ទើបជាអ្នក អស់សង្ស័យក្នុងទុក្ខ អស់សង្ស័យក្នុងហេតុឲ្យកើតទុក្ខ អស់ សង្ស័យក្នុងធម៌រំលត់ទុក្ខ អស់សង្ស័យក្នុងសេចក្តីប្រតិបត្តិ ទៅ

កាន់ទីរំលត់ទុក្ខ បពិត្រព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគ ក៏មានឧបការៈច្រើន ដល់ព្រះនាងមហាបជាបតិគោតមីដែរ ។

[ ១៨៤ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អើយ៉ាងហ្នឹងហើយ អានន្ទ អើយ៉ាងហ្នឹងហើយ អានន្ទ ម្នាលអានន្ទ បុគ្គលអាស្រ័យបុគ្គលណា ទើបបានដល់ព្រះពុទ្ធជាទីពឹង បានដល់ព្រះធម៌ជាទីពឹង បានដល់ព្រះសង្ឃជាទីពឹង ម្នាលអានន្ទ តថាគតមិនសម្តែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិ-កម្ម និងការឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ ជាបច្ច័យដល់អ្នកជំងឺ ថាជាកម្មដែលបុគ្គលនេះ តបស្នងដល់បុគ្គលនេះ បានដោយល្អឡើយ ។ ម្នាលអានន្ទ មួយទៀត បុគ្គលអាស្រ័យនូវបុគ្គលណា ហើយបានវៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ម្នាលអានន្ទ តថាគតមិនសម្តែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម និងការឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ ជាបច្ច័យដល់អ្នកជំងឺ ថាជាកម្មដែលបុគ្គលនេះ តបស្នងដល់បុគ្គលនេះ បានដោយល្អឡើយ ។

ម្នាលអានន្ទ មួយទៀត បុគ្គលអាស្រ័យនូវបុគ្គលណា ហើយ បានប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះសង្ឃ ប្រកបដោយសីលទាំងឡាយ ដែលជាទីត្រេកអរនៃព្រះអរិយបុគ្គល ម្នាលអានន្ទ តថាគតមិនសម្តែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម និងការឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ ជាបច្ច័យដល់អ្នកជំងឺ ថាជាកម្មដែលបុគ្គលនេះ តបស្នង ដល់បុគ្គលនេះ បានដោយល្អឡើយ ។ ម្នាលអានន្ទ មួយទៀត បុគ្គលអាស្រ័យនូវបុគ្គលណាហើយ ជាអ្នកអស់សង្ស័យក្នុងទុក្ខ អស់សង្ស័យក្នុងហេតុឲ្យកើតទុក្ខ អស់សង្ស័យក្នុងធម៌រំលត់ទុក្ខ អស់សង្ស័យក្នុងសេចក្តីប្រតិបត្តិទៅកាន់ធម៌រំលត់ទុក្ខ ម្នាលអានន្ទ តថាគតមិនសម្តែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម និងការឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ ជាបច្ច័យដល់អ្នកជំងឺ ថាជាកម្មដែលបុគ្គលនេះ តបស្នងដល់បុគ្គលនេះ បានដោយល្អឡើយ ។

[ ១៨៥ ] ម្នាលអានន្ទ បាដិបុគ្គលិកាទក្ខិណា ( ទានដែលឲ្យចំពោះបុគ្គល ) នេះ មាន ១៤ យ៉ាង ។ បុគ្គលឲ្យទានចំពោះ

ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នេះជាបាដិបុគ្គលិកាទក្ខិណាទី ១ ។ ឲ្យទានចំពោះព្រះបច្ចេកពុទ្ធ នេះជាបាដិបុគ្គលិកាទក្ខិណា ទី ២ ។ ឲ្យទានចំពោះព្រះអរហន្តជាសាវក របស់ព្រះតថាគត នេះជាបាដិបុគ្គលិកាទក្ខិណាទី ៣ ។ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល នេះជាបាដិបុគ្គលិកាទក្ខិ-ណា ទី ៤ ។ ឲ្យទានចំពោះអនាគាមិបុគ្គល នេះជាបាដិបុគ្គលិកា-ទក្ខិណា ទី ៥ ។ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល នេះជាបាដិបុគ្គលិកាទក្ខិណា ទី ៦ ។ ឲ្យទានចំពោះសកទាគាមិនបុគ្គល នេះជាបាដិបុគ្គលិកាទក្ខិណា ទី ៧ ។ ឲ្យទានចំពោះចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល នេះជាបាដិបុគ្គលិកាទក្ខិណា ទី ៨ ។ ឲ្យទានចំពោះសោតាបន្នបុគ្គល នេះជាបាដិបុគ្គលិកាទក្ខិណា ទី ៩ ។ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល[1] នេះជាបាដិបុគ្គលិកាទក្ខិណា ទី ១០ ។ ឲ្យទាន

---

*១ អដ្ឋកថាថា សូម្បីឧបាសកដល់សរណគមន៍ ៣ ក្តី កាន់សីល ៥ ក្តី សីល ១០ ក្តី សាមណេរ ឬភិក្ខុដែលទើបនឹងបួសបាន ១ ថ្ងៃក្តី ភិក្ខុមានវត្តប្រតិបត្តិដែលបួសយូរហើយក្តី ភិក្ខុទ្រទ្រង់វិបស្សនាក្តី ទាំងអស់នេះ ឈ្មោះថា ប្រតិបត្តិដើម្បីឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ តែបុគ្គលឲ្យទានចំពោះបុគ្គលទាំងអម្បាលនេះ បានផលច្រើនជាងគ្នាជាលំដាប់ ។*

ចំពោះអ្នកបួសក្រៅ ( ពុទ្ធសាសនា ) ដែលប្រាសចាកតម្រេកក្នុងកាម[2] ទាំងឡាយ នេះជាបាដិបុគ្គលិកាទក្ខិណា ទី ១១ ។ ឲ្យទានចំពោះបុថុជ្ជនមានសីល នេះជាបាដិបុគ្គលិកាទក្ខិណា ទី ១២ ។ ឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល នេះជាបាដិបុគ្គលិកា-ទក្ខិណា ទី ១៣ ។ ឲ្យទានចំពោះសត្វតិរច្ឆាន នេះជាបាដិបុគ្គលិ-កាទក្ខិណា ទី ១៤ ។

[ ១៨៦ ] ម្នាលអានន្ទ បណ្តាបុគ្គលអ្នកទទួលទានទាំងនោះ ទក្ខិណាមានគុណមួយរយ[3] ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះសត្វតិរច្ឆាន ។ ទក្ខិណាមានគុណមួយពាន់ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល ។ ទក្ខិណាមានគុណមួយសែន ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះ

---

២ សំដៅពួកអ្នកជាកម្មវាទី កិរិយវាទី ដែលបានអភិញ្ញាជាលោកិយទាំង ៥ ។

៣ អដ្ឋកថាថា ឲ្យនូវអានិសង្ស ១០០ គឺ ១០០ អត្តភាព ក្នុងអត្តភាពមួយ ៗ មានអាយុវែង ១ សម្បុរល្អ ១ សេចក្តីសុខ ១ កម្លាំង ១ ប្រាជ្ញា ១ រួមជាអានិសង្ស ៥០០ ។ ទានក្រៅពីសត្វតិរច្ឆានទៅ ក៏គុណជាប្រាំ ៗ តាមឧបាយនេះដែរ ។

បុថុជ្ជនមានសីល ។ ទក្ខិណាមានគុណមួយសែនកោដិ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះអ្នកបួសខាងក្រៅ ដែលប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។ ទក្ខិណាមានគុណរាប់មិនបានប្រមាណមិនកើត ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ នឹងបាច់និយាយទៅថ្វី ( ដល់ទក្ខិណាដែលបុគ្គលឲ្យ ) ចំពោះសោតាបន្នបុគ្គល នឹងនិយាយថ្វី ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល នឹងនិយាយទៅថ្វី ចំពោះសកទាគាមិបុគ្គល នឹងនិយាយទៅថ្វី ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល នឹងនិយាយទៅថ្វី ចំពោះអនាគាមិបុគ្គល នឹងនិយាយទៅថ្វី ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល នឹងនិយាយទៅថ្វី ចំពោះព្រះអរហន្តជាសាវករបស់តថាគត នឹងនិយាយទៅថ្វី ចំពោះព្រះ-បច្ចេកពុទ្ធ នឹងនិយាយទៅថ្វី ចំពោះព្រះតថាគត ជាអរហន្ត-សម្មាសម្ពុទ្ធ ។

[ ១៨៧ ] ម្នាលអានន្ទ សង្ឃគតាទក្ខិណា ( ទានដែលតម្កល់ក្នុងសង្ឃ ) នេះ មាន ៧ យ៉ាង ។ បុគ្គលឲ្យទាន ចំពោះសង្ឃទាំងពីរ

ចំណែក មានព្រះពុទ្ធជាប្រធាន[4] នេះជាសង្ឃគតាទក្ខិណា ទី ១ ។ កាលបើព្រះតថាគតបរិនិព្វានទៅ បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក នេះជាសង្ឃគតាទក្ខិណា ទីពីរ ។ ឲ្យទានចំពោះតែភិក្ខុសង្ឃ នេះជាសង្ឃគតាទក្ខិណា ទី ៣ ។ ឲ្យទានចំពោះតែភិក្ខុនី-សង្ឃ នេះជាសង្ឃគតាទក្ខិណា ទី ៤ ។ បុគ្គល ( ទៅនិមន្តអំពីសម្មាក់សង្ឃ ) ថា សូមលោកទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណេះ ពួក

---

៤ សង្ឃទាំងពីរចំណែក គឺពួកភិក្ខុសង្ឃអង្គុយម្ខាង ពួកភិក្ខុនីសង្ឃអង្គុយម្ខាង ព្រះសាស្តាជាម្ចាស់ គង់ត្រង់កណ្តាល ដូច្នេះហៅថា សង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធាន ។ សង្ឃគតាទក្ខិណាទី ១ នេះ គ្មានទក្ខិណាណាវិសេសស្មើឡើយ ។ ប៉ុន្តែ កាលដែលព្រះសាស្តាបរិនិព្វានទៅហើយនោះ គេតម្កល់ព្រះពុទ្ធប្បដិមា ឬព្រះធាតុ លើអាសនៈក្នុងទីចំពោះមុខសង្ឃទាំងពីរចំណែក តម្កល់ម្ហូបចំណីលើតុ ឬជើងស្រាបហើយ ធ្វើកិច្ចទក្ខិណោទកជាដើម ថ្វាយវត្ថុទាំងពួង ដល់ព្រះសាស្តាជាមុន ទើបថ្វាយសង្ឃទាំងពីរចំណែក ជាក្រោយ យ៉ាងនេះ ក៏ឈ្មោះថា ថ្វាយទានដល់សង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធានដែរ ( សម័យឥឡូវនេះ គ្មានភិក្ខុនី មានតែភិក្ខុ ដូច្នេះ ឈ្មោះថា ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ) ។ ភោជន ដែលថ្វាយដល់ព្រះសាស្តាយ៉ាងនេះ ត្រូវប្រគេនដល់ភិក្ខុណា ដែលប្រតិបត្តិព្រះសាស្តា ដ៏បរិបូណ៌ដោយវត្តប្រតិបត្តិ ព្រោះជាវត្ថុរបស់ព្រះពុទ្ធជាបិតា ត្រូវបានដល់ភិក្ខុជាកូន ឬនឹងប្រគេនដល់សង្ឃក៏គួរ ។ បើវត្ថុនោះ ជាប្រេង ឬសាជក ត្រូវអុជប្រទីប ចងជាទង់ ឬពិដានថ្វាយ ។ អដ្ឋកថា ។

ភិក្ខុនីប៉ុណ្ណោះ អំពីសង្ឃ ដើម្បីខ្ញុំ ហើយទើបឲ្យទាន នេះជាសង្ឃគតាទក្ខិណា ទី ៥ ។ បុគ្គល ( ទៅនិមន្តអំពីសម្នាក់សង្ឃ ) ថា សូមលោកទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណោះ អំពីសង្ឃ ដើម្បីខ្ញុំ ហើយទើបឲ្យទាន នេះជាសង្ឃគតាទក្ខិណា ទី ៦ ។ បុគ្គល ( ទៅនិមន្តអំពីសម្នាក់សង្ឃ ) ថា សូមលោកទាំងឡាយ ចាត់ពួកភិក្ខុនីប៉ុណ្ណោះ អំពីសង្ឃ ដើម្បីខ្ញុំ ហើយទើបឲ្យទាន នេះជាសង្ឃគតា-ទក្ខិណា ទី ៧ ។

[ ១៨៨ ] ម្នាលអានន្ទ ក្នុងកាលជាអនាគត នឹងមានគោត្រភូសង្ឃ ( សង្ឃមានតែឈ្មោះ ) មានតែសំពត់កាសាវៈចងក ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ជនទាំងនោះ ឧទ្ទិសចំពោះសង្ឃ ហើយនឹងឲ្យទានដល់បុគ្គលទ្រុស្តសីលទាំងនោះ ម្នាលអានន្ទ សូម្បីក្នុងកាលនោះ ក៏តថាគតពោលថា សង្ឃគតា-ទក្ខិណាទាន មានអានិសង្សរាប់មិនបាន ប្រមាណមិនកើតដែរ ម្នាលអានន្ទ តថាគតមិនដែលពោលនូវបាដិបុគ្គលិកទាន ថាមានផលច្រើន ជាងសង្ឃគតាទក្ខិណាទាន ដោយបរិយាយណាមួយឡើយ ។

[ ១៨៩ ] ម្នាលអានន្ទ ទក្ខិណាវិសុទ្ធិ ( ការបរិសុទ្ធិ និងមិនបរិសុទ្ធិរបស់ទាន ) នេះ មាន ៤ យ៉ាង ។ ឯទក្ខិណាវិសុទ្ធិទាំង ៤

តើដូចម្តេច ។ ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួល ១ ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកទទួល មិនបរិសុទ្ធខាងអ្នកឲ្យ ១ ម្នាលអានន្ទ ទក្ខិណា មិនបរិសុទ្ធខាងអ្នកឲ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង ១ ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យផង បរិសុទ្ធខាងអ្នកទទួលផង ១ ។

[ ១៩០ ] ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួល តើដូចម្តេច ។ ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាបុគ្គលមានសីល មានធម៌ល្អ ឯពួកអ្នកទទួលជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ម្នាលអានន្ទ យ៉ាងនេះឯងឈ្មោះថា ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួល ។

[ ១៩១ ] ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកទទួល មិនបរិសុទ្ធខាងអ្នកឲ្យ តើដូចម្តេច ។ ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាបុគ្គលទ្រុស្តសីល មានធម៌ដ៏លាមក ឯពួកអ្នកទទួលជាបុគ្គលមានសីល មានធម៌ល្អ ម្នាលអានន្ទ យ៉ាងនេះឯងឈ្មោះថា ទក្ខិណា បរិសុទ្ធខាងអ្នកទទួល មិនបរិសុទ្ធខាងអ្នកឲ្យ ។

[ ១៩២ ] ម្នាលអានន្ទ ទក្ខិណា មិនបរិសុទ្ធខាងអ្នកឲ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង តើដូចម្តេច ។ ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ទាំងពួកអ្នកទទួល ក៏ជាបុគ្គលទ្រុស្តសីល មានធម៌ដ៏លាមកដូចគ្នា ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថា ទក្ខិណា មិនបរិសុទ្ធខាងអ្នកឲ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង ។

[ ១៩៣ ] ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យផង បរិសុទ្ធខាងអ្នកទទួលផង តើដូចម្តេច ។ ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាបុគ្គលមានសីល មានធម៌ល្អ ទាំងពួកអ្នកទទួល ក៏ជាបុគ្គលមានសីល មានធម៌ល្អដូចគ្នា ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថា ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យផង បរិសុទ្ធខាងអ្នកទទួលផង ។

ម្នាលអានន្ទ នេះឯង ជាទក្ខិណាវិសុទ្ធិ ៤ យ៉ាង ។

[ ១៩៤ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់នូវព្រះសូត្រនេះ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់នូវព្រះសូត្រនេះ រួចហើយ ទើបទ្រង់ត្រាស់នូវព្រះគាថាតទៅទៀតដូច្នេះថា ៖

បុគ្គលណា ជាអ្នកមានសីល មានចិត្តជ្រះថ្លាដោយ
ប្រពៃ ជឿស៊ប់នូវកម្ម និងផល របស់កម្មដ៏លើស

លុប ឲ្យទានដែលខ្លួនបានមកដោយធម៌ ចំពោះពួក បុគ្គលទ្រុស្តសីល ទក្ខិណានោះ បរិសុទ្ធខាងអ្នកឲ្យ បុគ្គលណា ជាអ្នកទ្រុស្តសីល មានចិត្តមិនបានជ្រះ ថ្លា មិនជឿស៊ប់នូវកម្ម និងផល របស់កម្មដ៏លើស លុប ឲ្យទានដែលខ្លួនបានមកមិនដោយធម៌ ចំពោះ ពួកបុគ្គលអ្នកមានសីល ទក្ខិណានោះ បរិសុទ្ធ ខាងអ្នកទទួល បុគ្គលណា ជាអ្នកទ្រុស្តសីល មាន ចិត្តមិនបានជ្រះថ្លា មិនជឿស៊ប់នូវកម្ម និងផល របស់កម្ម ដ៏លើសលុប ឲ្យទានដែលខ្លួនបានមកមិន ដោយធម៌ ចំពោះពួកបុគ្គលទ្រុស្តសីល តថាគត មិនពោលថា ទាននោះ មានផលដ៏បរិបូណ៌ទេ បុគ្គល ណា ជាអ្នកមានសីល មានចិត្តជ្រះថ្លាដោយប្រពៃ ជឿស៊ប់នូវកម្ម និងផលរបស់កម្ម ដ៏លើសលុប ឲ្យ ទានដែលខ្លួនបានមកដោយធម៌ ចំពោះពួកបុគ្គល មានសីល តថាគតពោលថា ទាននោះឯង ទើប បានផលដ៏បរិបូណ៌ បុគ្គលណា ជាអ្នកប្រាសចាក រាគៈ មានចិត្តជ្រះថ្លាដោយប្រពៃ ជឿស៊ប់នូវកម្ម និងផល របស់កម្ម ដ៏លើសលប់ ឲ្យទានដែលខ្លួន

បានមកដោយធម៌ ចំពោះពួកបុគ្គលប្រាសចាក រាគៈ ទាននោះឯង ប្រសើរជាងពួកអាមិសទាន ( ទាំងអស់ ) ។

ចប់ ទក្ខិណាវិភង្គសូត្រ ។

# មច្ឆរិសូត្រ

## ( បិដក ២៩ ទំព័រ ៥០ )

ធម្មំ ចរេ យោបិ សមុញ្ជកំ ចរេ
ទារំ ច បោសំ ទទំ អប្បកស្មឹ
សតំ សហស្សាន សហស្សយាគិនំ
កលំបិ នាគ្ឃន្តិ តថាវិធស្ស តេតិ ។

ជនណាចិញ្ចឹមកិរិយាផង កាលបើទ្រព្យមានតិច នៅតែឲ្យទានបានផង ប្រព្រឹត្តធម៌បានផង ប្រព្រឹត្តនូវសេចក្ដីខ្វល់ខ្វាយ ( ក្នុងការងារ ) ផង ពួកជនដែលមានការបូជារាប់ពាន់ ដល់បុគ្គលមួយសែននាក់ នៅតែមិនដល់មួយចំណិតរបស់បុគ្គល យ៉ាងនោះបាន ។

ទទន្តិ ហេកេ វិសមេ និវិដ្ឋា
ឃត្វា វធិត្វា អថ សោចយិត្វា

សា ទក្ខិណា អសុ្សមុខា សទណ្ឌា
សមេន ទិន្នស្ស ន អគ្ឃមេតិ
ឯវំ សហស្សាន សហស្សយាគិនំ
កលំបិ នាគ្ឃន្តិ តថាវិធស្ស តេតិ ។

បុគ្គលពួកមួយ បានឋិតនៅស៊ប់ក្នុងធម៌មិនស្មើ ហើយបៀតបៀន សម្លាប់ ពុំនោះសោត ធ្វើបុគ្គលដទៃឲ្យសោកសៅ ទើបឲ្យទាន ទក្ខិណាទាននោះ ឈ្មោះថា មានមុខទទឹកដោយទឹកភ្នែក ប្រកបដោយអាជ្ញា មិនដល់នូវតម្លៃនៃទាន ដែលបុគ្គលឲ្យហើយដោយធម៌ដ៏ស្មើទេ បុគ្គលមានការបូជារាប់ពាន់ ដល់បុគ្គលមួយពាន់នាក់នោះ នៅតែមិនដល់មួយចំណិតរបស់បុគ្គលយ៉ាងនោះ ដូច្នេះឯង ។

## អដ្ឋកថា

## សេចក្តីប្រែនៅក្នុងសៀវភៅ ទានកថា

## រៀបរៀងដោយលោកគ្រូ អគ្គបណ្ឌិត ប៊ុត សាវង្ស

បុគ្គលណា ចិញ្ចឹមភរិយាផង ប្រព្រឹត្តធម៌ គឺកុសល-កម្មបថ ១០ បានផង ប្រព្រឹត្តស្អាតក្នុងការងារបានផង កាលបើទ្រព្យមានតិច នៅតែឲ្យទានបានផង ( ទាននៃបុគ្គលអ្នកប្រព្រឹត្តធម៌នេះ ប្រសើរក្រៃលែងណាស់ ) សូម្បី

បុរសមួយសែននាក់ បូជាចំពោះភិក្ខុមួយពាន់អង្គ ឬ បរិច្ចាគទ្រព្យ ម្នាក់មួយពាន់កហាបណៈ រួមគ្នាទៅបាន ដប់កោដិកហាបណៈ ( ប្រាក់ច្រើនដល់ម៉ឺន ) នៅតែ មិនដល់មួយភាគរយ នៃទានរបស់បុគ្គលអ្នកប្រព្រឹត្តធម៌ ដែលបានឲ្យស្បូវ្យទ្រព្យតិចតួច ។

បុគ្គលពួកមួយ បានតាំងនៅស៊ប់ក្នុងធម៌មិនស្មើ ហើយបៀតបៀន សម្លាប់ ពុំនោះសោត ធ្វើបុគ្គលដទៃ ឲ្យសោកសៅ ទើបឲ្យទាន ទក្ខិណាទាននោះ ឈ្មោះថា មានមុខ ទទឹកដោយទឹកភ្នែក ប្រកបដោយអាជ្ញា មិនដល់ នូវតម្លៃនៃទាន ដែលបុគ្គលឲ្យហើយដោយធម៌ដ៏ស្មើទេ ។ អដ្ឋកថា បានបញ្ចប់សេចក្តីនេះ ដោយពាក្យថា មហាទាន នេះ ឈ្មោះថា មានផលតិច ព្រោះភាពមិនបរិសុទ្ធ កើត ឡើងក្នុងខ្លួន ចំណែកទានដោយទ្រព្យតិច ឈ្មោះថា មាន ផលច្រើន ព្រោះភាពបរិសុទ្ធកើតឡើងក្នុងខ្លួន ដោយ ប្រការដូច្នេះ ។

# វេលាមព្រាហ្មណ៍
# ( បិដក ៤៩ ទំព័រ ៧៧-៨៣ )

[ ២០ ] *សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលគហបតី ទានក្នុងត្រកូលអ្នកនៅតែឲ្យដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ទានក្នុងត្រកូលខ្ញុំព្រះអង្គ នៅតែឲ្យដែរ តែទាននោះឯង សៅហ្មង គឺបាយចុងអង្ករ និងទឹកជ្រក់ ជាគម្រប់ពីរ ។ ម្នាលគហបតី បុគ្គលឲ្យទានសៅហ្មងក្តី ឲ្យទានថ្លៃថ្លាក្តី តែឲ្យទាននោះ មិនគោរព ធ្វើសេចក្តីមិនកោតក្រែងហើយឲ្យ មិនឲ្យដោយដៃខ្លួនឯង បោះឲ្យ យល់ថា មិនមានផលហើយឲ្យ វិបាករបស់ទាននោះ ៗ កើតក្នុងត្រកូលណា ៗ ចិត្តក៏មិនឱនទៅ ដើម្បីប្រើប្រាស់នូវភត្តដ៏ថ្លៃថ្លា ចិត្តមិនឱនទៅ ដើម្បីប្រើប្រាស់នូវសំពត់ដ៏ថ្លៃថ្លា ចិត្តមិនឱនទៅ ដើម្បីប្រើប្រាស់យានដ៏ថ្លៃថ្លា ចិត្តមិនឱនទៅ ដើម្បីប្រើប្រាស់ក្នុងកាមគុណ ៥ ដ៏ថ្លៃថ្លា មួយទៀត ពួកជនណា ដែល*

ជាកូនក្តី ប្រពន្ធក្តី ទាសៈក្តី អ្នកបម្រើក្តី កម្មករក្តី របស់បុគ្គល នោះ ជនទាំងនោះ មិនស្តាប់ មិនផ្ចង់ត្រចៀកស្តាប់ រមែងបញ្ជូនចិត្តទៅក្នុងអារម្មណ៍ដទៃ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលគហបតី ព្រោះថា វិបាកនៃកម្មទាំងឡាយ ដែលបុគ្គលធ្វើដោយមិនគោរព រមែងមានយ៉ាងនេះឯង ម្នាលគហបតី បុគ្គលឲ្យទានសោហ្មងក្តី ថ្លៃថ្លាក្តី តែឲ្យទាននោះ ដោយគោរព ធ្វើសេចក្តីកោតក្រែងហើយឲ្យ ឲ្យដោយដៃខ្លួនឯង មិនបោះឲ្យ យល់ថាមានផលហើយឲ្យ វិបាករបស់ទាននោះ ៗ កើតក្នុងត្រកូលណា ៗ ចិត្តក៏រមែងឱនទៅ ដើម្បីប្រើប្រាស់ភត្តដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅដើម្បីប្រើប្រាស់សំពត់ដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅ ដើម្បីប្រើប្រាស់យានដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅ ដើម្បីប្រើប្រាស់ក្នុងកាមគុណ ៥ ដ៏ថ្លៃថ្លា មួយទៀត ពួកជនណា ដែលជាកូនក្តី ប្រពន្ធក្តី ទាសៈក្តី អ្នកបម្រើក្តី កម្មករក្តី របស់បុគ្គលនោះ ជនទាំងនោះ រមែងស្តាប់ ផ្ចង់ត្រចៀកស្តាប់ មិនបញ្ជូនចិត្តទៅក្នុងអារម្មណ៍ដទៃឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលគហបតី ព្រោះថា វិបាករបស់កម្មទាំងឡាយ ដែលបុគ្គលធ្វើដោយគោរព រមែងមានយ៉ាងនេះឯង ។ ម្នាលគហបតី កាលពីព្រេងនាយ មានព្រាហ្មណ៍ឈ្មោះវេលាម លោកបានឲ្យទាន ជាមហាទាន មានសភាពយ៉ាងនេះ

គឺបានឲ្យភាជន៍មាស ៨៤.០០០ ដែលពេញដោយប្រាក់ បានឲ្យភាជន៍ប្រាក់ ៨៤.០០០ ដែលពេញដោយមាស បានឲ្យភាជន៍សំរិទ្ធ ៨៤.០០០ ដែលពេញដោយប្រាក់ បានឲ្យដំរី ៨៤.០០០ ដែលមានគ្រឿងអលង្ការមាស មានទង់ជ័យមាស ព្រមទាំងបាំងដោយបណ្ដាញមាស បានឲ្យរថ ៨៤.០០០ ដែលពាសដោយស្បែកសីហៈ ដែលពាសដោយស្បែកខ្លាធំ ពាសដោយស្បែកខ្លាដំបង ពាសដោយសំពត់កម្ពល មានពណ៌លឿង មានគ្រឿងអលង្ការមាស មានទង់ជ័យមាស បិទបាំងដោយបណ្ដាញមាស បានឲ្យមេគោ ៨៤.០០០ សម្រាប់រូតបង្ហូរ ( ទឹកដោះ ) មានភាជន៍សំរិទ្ធិសម្រាប់ត្រង បានឲ្យនាងកញ្ញា ៨៤.០០០ ដែលពាក់កែវមណី និងកុណ្ឌល បានឲ្យបល្ល័ង្ក ៨៤.០០០ ដែលក្រាលដោយព្រំ ក្រាលដោយកម្រាលរោមមានពណ៌ស ក្រាលដោយកម្រាលរោមមានផ្កាជាចង្កោម ក្រាលដោយកម្រាលដ៏ប្រសើរ ធ្វើពីរោមម្រឹក ឈ្មុស មានខ្នើយមានពណ៌ក្រហមទាំងពីរខាង ព្រមទាំងពិតានមានពណ៌ក្រហម បានឲ្យកោដិ[5] នៃសំពត់ ៨៤.០០០ គឺសំពត់ឬីមានសាច់ល្អិត សំពត់សូត្រមានសាច់ល្អិត សំពត់

[5] កោដិ ក្នុងទីនេះ សំដៅយក សំពត់សាដក ១០ ហៅថា មួយកោដិ ។ អដ្ឋកថា ។

អំបោះមានសាច់ល្អិត បាច់និយាយថ្វី ដល់បាយ ទឹក បង្អែម ភោជន គ្រឿងលាប ទីដេក ដូចជាស្ទឹងតែងហូរទៅ ម្នាល គហបតី អ្នកប្រហែលជាមានសេចក្ដីសម្គាល់ នូវវេលាម-ព្រាហ្មណ៍នុ៎ះ យ៉ាងនេះថា ក្នុងសម័យនោះ វេលាមព្រាហ្មណ៍ ជាបុគ្គលដទៃដោយពិត ( ក្រៅពីតថាគត ) លោកបានឲ្យទាន នោះ ជាមហាទាន ។ ម្នាលគហបតី ហេតុនុ៎ះ អ្នកមិនត្រូវយល់ យ៉ាងនេះឡើយ ក្នុងសម័យនោះ វេលាមព្រាហ្មណ៍ ក៏គឺតថាគត ទានដែលតថាគតបានឲ្យនោះ ជាមហាទាន ។ ម្នាលគហបតី មិនមានទក្ខិណេយ្យបុគ្គលណាមួយ ក្នុងទាននោះទេ មិនមាន បុគ្គលណាមួយ សម្អាតទក្ខិណាទាននោះទេ ។ ម្នាលគហបតី វេលាមព្រាហ្មណ៍បានឲ្យទានណា ដែលឈ្មោះថា មហាទាន និង បុគ្គលណា ញុំាងបុគ្គលដែលមានទិដ្ឋិល្អ ១ រូប ( សោតាបន្នបុគ្គល ) ឲ្យបរិភោគទាននេះ ជាទានមានផលច្រើនជាងមហាទាន បុគ្គល ណា ញុំាងបុគ្គលដែលមានទិដ្ឋិល្អ ១០០ រូប ឲ្យបរិភោគ និងបុគ្គល ណា ញុំាងបុគ្គលជាសកទាគាមី ១ រូប ឲ្យបរិភោគ ។ បេ ។ បុគ្គល ណា ញុំាងបុគ្គលជាសកទាគាមី ១០០ រូប ឲ្យបរិភោគ និងបុគ្គលណា ញុំាងបុគ្គលជាអនាគាមី ១ រូប ឲ្យបរិភោគ បើ បុគ្គលណា ញុំាងបុគ្គលជាអនាគាមី ១០០ រូប ឲ្យបរិភោគ និង

បុគ្គលណា ញុំាំងបុគ្គលជាព្រះអរហន្ត ១ រូប ឲ្យបរិភោគ បុគ្គលណា ញុំាំងបុគ្គលជាព្រះអរហន្ត ១០០ រូប ឲ្យបរិភោគ និងបុគ្គលណា ញុំាំងព្រះបច្ចេកពុទ្ធ ១ អង្គ ឲ្យបរិភោគ បុគ្គលណា ញុំាំងព្រះបច្ចេកពុទ្ធ ១០០ អង្គ ឲ្យបរិភោគ និងបុគ្គលណា ញុំាំងព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ឲ្យបរិភោគ បុគ្គលណា ញុំាំងសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យបរិភោគ និងបុគ្គលណា ឲ្យគេធ្វើវិហារ ឧទ្ទិសចំពោះសង្ឃមកពីទិសទាំង ៤ បុគ្គលណា មានចិត្តជ្រះថ្លាដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង និងបុគ្គលណា មានចិត្តជ្រះថ្លាសមាទាននូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ដោយការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ បុគ្គលណា មានចិត្តជ្រះថ្លា សមាទាននូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត ។ បេ ។ វៀរចាកហេតុជាទីពឹង នៃសេចក្តីប្រមាទ ដោយការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យដោយហោចទៅ បុគ្គលណា ចម្រើននូវមេត្តាចិត្ត សូម្បីអស់កាលត្រឹមតែមួយរូតទឹកដោះគោប៉ុណ្ណោះ ការចម្រើនមេត្តាចិត្តនេះ របស់បុគ្គលទាំងនោះ មានផលច្រើន ជាងទាននោះទៅ

ទៀត ។ ម្នាលគហបតី វេលាមព្រាហ្មណ៍ បានឲ្យទាន ជាមហាទានណា និងបុគ្គលណា ញ៉ាំងបុគ្គលមានទិដ្ឋិល្អ ១ រូប ឲ្យបរិភោគ បុគ្គលណា ញ៉ាំងបុគ្គលមានទិដ្ឋិល្អ ១០០ រូប ឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងបុគ្គលជាសកទាគាមី ១ រូប ឲ្យបរិភោគ បុគ្គលណា ញ៉ាំងបុគ្គលជាសកទាគាមី ១០០ រូប ឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងបុគ្គលជាអនាគាមី ១ រូប ឲ្យបរិភោគ បុគ្គលណា ញ៉ាំងបុគ្គលជាអនាគាមី ១០០ រូប ឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងព្រះអរហន្ត ១ អង្គ ឲ្យបរិភោគ បុគ្គលណា ញ៉ាំងព្រះអរហន្ត ១០០ អង្គ ឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងព្រះបច្ចេកពុទ្ធ ១ អង្គ ឲ្យបរិភោគ បុគ្គលណា ញ៉ាំងពួកព្រះបច្ចេកពុទ្ធ ១០០ អង្គ ឲ្យបរិភោគ និងបុគ្គលណា ញ៉ាំងព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ឲ្យបរិភោគ បុគ្គលណា ញ៉ាំងភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យបរិភោគ និងបុគ្គលណា ឲ្យគេធ្វើវិហារ ឧទ្ទិសចំពោះសង្ឃមកអំពីទិសទាំង ៤ បុគ្គលណាមានចិត្តជ្រះថ្លាដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង និងបុគ្គលណា មានចិត្តជ្រះថ្លា សមាទាននូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត ។ បេ ។ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ដោយការផឹកនូវទឹកស្រវឹង គឺ

សុរា និងមេរ័យ ដោយហោចទៅ និងបុគ្គលណា ចម្រើនទូវមេត្តាចិត្ត សូម្បីអស់កាលត្រឹមតែមួយរូតទឹកដោះគោប៉ុណ្ណោះ និងបុគ្គលណា ចម្រើនទូវអនិច្ចសញ្ញា សូម្បីអស់កាលគ្រាន់តែផ្ទាត់ម្រាមដៃប៉ុណ្ណោះ ការចម្រើននេះ មានផលច្រើនជាងទាននោះទៅទៀត ។

## អានិសង្ស ១០ យ៉ាងនៃបបរ
## ( បិដក ៧ ទំព័រ ២៨៧ )

គឺបុគ្គលអ្នកឲ្យបបរឈ្មោះថា ឲ្យអាយុ ១ ឲ្យពណ៌សម្បុរ ១ ឲ្យសេចក្តីសុខ ១ ឲ្យកម្លាំងកាយ ១ ឲ្យប្រាជ្ញា ១ បបរដែលបុគ្គលហុតទៅហើយ រមែងហាមឃាត់សេចក្តីឃ្លាន ១ បន្ទោបង់សេចក្តីស្រេក ១ ញុំាងខ្យល់ឲ្យដើរទៅស្រួល ១ ញុំាងសរសៃឲ្យស្អាត ១ ញុំាងអាហារថ្មីដ៏សេសសល់ឲ្យរលួយ ១ ។

# អានិសង្សនៃបុគ្គលមានសីល នៃសីលសម្បទា ៥ ប្រការ ( បិដក ១៦ ទំព័រ ១៨៥-១៨៦ )

( ១ ) រមែងបានគំនរទ្រព្យដ៏ធំ ដែលមានសេចក្ដីមិនប្រមាទជាហេតុ ( ២ ) មានកិត្តិស័ព្ទដ៏ពីរោះ តែងផ្សាយទៅសព្វទិស ( ៣ ) ទោះចូលទៅរកបរិស័ទណា ៗ គឺខត្តិយបរិស័ទក្ដី ព្រាហ្មណ-បរិស័ទក្ដី គហបតីបរិស័ទក្ដី សមណបរិស័ទក្ដី ជាបុគ្គលមានសេចក្ដីក្លៀវក្លា ចូលទៅដោយការមិនអៀនអន់ ( ៤ ) ជាបុគ្គលមិនវង្វេង ធ្វើមរណកាល ( ៥ ) លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងកើតក្នុងលោក គឺមនុស្ស សុគតិ និងស្ថានសួគ៌ ។

# ផលទាន ៥ ប្រការ ( នៅក្នុងសីហសូត្រ ) ( បិដក ៤៤ ទំព័រ ៧៦-៧៧ )

( ១ ) ទាយកអ្នកម្ចាស់ទាន ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ( ២ ) ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ រមែងរាប់រកទាយកអ្នកម្ចាស់ទាន ( ៣ ) កិត្តិស័ព្ទដ៏ពីរោះ របស់ទាយកអ្នកម្ចាស់ទាន រមែងខ្ចរខ្ចាយទៅ ( ៤ ) ទាយកម្ចាស់ទានចូលទៅ

កាន់បរិស័ទណា ទោះជាខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតីបរិស័ទក្តី សមណបរិស័ទក្តី រមែងក្លៀវក្លា មិនមានសេចក្តីអៀនខ្មាស ( ៥ ) ទាយកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។

# អនាថបណ្ឌិកសេដ្ឋី

## ( បិដកលេខ ១០ ទំព័រ ២៩២-២៩៦ )

[ ៣៥៥ ] គ្រានោះ អនាថបិណ្ឌិកគហបតីគិតថា ឥឡូវនេះ វេលាថ្ងៃស្អែកនេះ អញនឹងចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ទើបគួរ គិតហើយក៏តម្កល់ស្មារតីចំពោះទៅរកព្រះពុទ្ធជាអារម្មណ៍ ហើយក៏ដេកទៅ ក៏ក្នុងវេលាយប់ ( នោះ ) អនាថបិណ្ឌិកគហបតីស្មានថាភ្លឺហើយ ក៏ក្រោកឡើង ៣ ដង ។ លំដាប់នោះ អនាថបិណ្ឌិកគហបតីចូលទៅកាន់ទ្វារសីតវន ( ព្រៃត្រជាក់ ) ។ ពួកអមនុស្សក៏នាំគ្នាបើកទ្វារឲ្យ ។ កាលអនាថបិណ្ឌិកគហបតីចេញផុតអំពីនគរហើយ ពន្លឺក៏បាត់ទៅវិញ ។ ស្រាប់តែមានងងឹតកើតឡើង ។ ភ័យសេចក្តីតក់ស្លុតនិងព្រឺរោមក៏កើតឡើង ។ អនាថបិណ្ឌិកគហបតីចង់ត្រឡប់អំពីទីនោះមកវិញ ។

[ ៣៥៦ ] គ្រានោះ សីវកយក្សដែលបាត់ទៅ ក៏បញ្ចេញសំឡេងឡើងថា ដំរី ១ សែន សេះ ១ សែន រថទឹមដោយមេសេះអស្សតរ ១ សែន ស្រីជំទង់ដែលប្រដាប់ដោយកុណ្ឌល ជាវិការៈនៃកែវមណី ១ សែន ក៏មិនដល់មួយចំណិតនៃការឈានទៅ ១ ជំហាន ដែលបណ្ឌិតចែកឲ្យជាចំណែក ១៦ អស់វារៈ ១៦ ដងទេ ។ ម្នាលគហបតី អ្នកចូរឈានដើរទៅ ម្នាលគហបតី អ្នកចូរឈានដើរទៅ ការឈានដើរទៅរបស់អ្នក ប្រសើរណាស់ ការត្រឡប់ទៅវិញមិនប្រសើរទេ ។

[ ៣៥៧ ] លំដាប់នោះ អនាថបិណ្ឌិកគហបតី ក៏បាត់ងងឹតទៅវិញ ។ ពន្លឺភ្លឺក៏កើតប្រាកដឡើង ។ ភ័យសេចក្តីតក់ស្លុតព្រឺរោមនោះឯង ក៏រម្ងាប់បាត់ទៅ ។ អនាថបិណ្ឌិកគហបតី ក៏បាត់ពន្លឺអស់វារៈពីរដងផង ។ បេ ។ អស់វារៈបីដងផង ។ ងងឹតក៏កើតប្រាកដឡើង ។ ភ័យសេចក្តីតក់ស្លុត ព្រឺរោមក៏កើតឡើង ។ អនាថបិណ្ឌិកគហបតីចង់ត្រឡប់អំពីទីនោះមកវិញ សីវកយក្សដែលបាត់ទៅហើយនោះ ស្រាប់តែបញ្ចេញសំឡេងអស់វារៈជាគម្រប់បីដងថា

ដំរី ១ សែន សេះ ១ សែន រថដែលទឹមដោយមេសេះ អស្សតរ ១ សែន ស្រីជំទង់ ដែលពាក់កុណ្ឌលជាវិការៈនៃកែវមណី ១ សែន មិនដល់ចំណិតនៃការឈានទៅ ១ ជំហាន ដែលបណ្ឌិតចែកឲ្យជាចំណែក ១៦ អស់វារៈ ១៦ ដងទេ ។

ម្នាលគហបតី អ្នកចូរឈានដើរទៅ ម្នាលគហបតី អ្នកចូរឈានដើរទៅ ការឈានដើរទៅរបស់អ្នក ប្រសើរណាស់ ដំណើរត្រឡប់ថយក្រោយវិញ មិនប្រសើរទេ ។ អនាថបិណ្ឌិកគហបតី ក៏បាត់ងងឹតទៅវិញ អស់វារៈបីដង ។ ពន្លឺក៏កើតប្រាកដឡើង ។ ភ័យសេចក្ដីតក់ស្លុតព្រឺរោមនោះ ឯងក៏រម្ងាប់ទៅ ។ លំដាប់នោះ អនាថបិណ្ឌិកគហបតីចូលទៅកាន់សីតវន ។

[៣៥៨] សម័យនោះឯង ព្រះមានព្រះភាគទ្រង់តើនឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយទ្រង់ចង្ក្រមក្នុងទីវាល ។ ព្រះមានព្រះភាគទ្រង់ទតឃើញអនាថបិណ្ឌិកគហបតី ដើរមកពីចម្ងាយលឹម ៗ លុះទ្រង់ទតឃើញហើយក៏ថយចុះអំពីទីចង្ក្រម ទ្រង់គង់លើអាសនៈដែលគេតាក់តែងថ្វាយស្រាប់ ។ ព្រះមានព្រះភាគទ្រង់គង់ហើយ ទើបមានព្រះបន្ទូលនេះ ទៅនឹងអនាថបិណ្ឌិកគហបតីថា ម្នាលសុទត្ត អ្នកចូរមកនេះ ។ ឯអនាថបិណ្ឌិក-

គហបតី មានចិត្តត្រេកអររីករាយដោយគិតថា ព្រះមានព្រះ-ភាគទ្រង់មានព្រះបន្ទូលត្រាស់ហៅ អាត្មាអញចំឈ្មោះ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបទៀបព្រះបាទទាំងគូ នៃព្រះមានព្រះភាគ ហើយក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ផ្ទំស្កប់ស្រួលទេឬ ។

[ ៣៥៩ ] ព្រះអង្គទ្រង់ត្រាស់ថា បុគ្គលណាមានសេចក្តីត្រជាក់ មិនមានកិលេសគ្រឿងសៅហ្មង មិនជាប់នៅក្នុងកាមទាំងឡាយ បុគ្គលនោះ ឈ្មោះថា ព្រាហ្មណ៍ អ្នកមានទុក្ខរំលត់ហើយ រមែងដេកនៅជាសុខគ្រប់កាលទាំងពួង ។ ( មនុស្សណា ) កាត់បង់នូវសេចក្តីប្រាថ្នា ក្នុងភពទាំងពួង ហើយនាំបង់នូវសេចក្តីក្រវល់ក្រវាយ ក្នុងហឫទ័យចេញ ( មនុស្សនោះ ) ឈ្មោះថា ជាអ្នកស្ងប់រម្ងាប់ ដល់ហើយនូវសេចក្តីរម្ងាប់នៃចិត្ត រមែងដេកនៅជាសុខ ។

[ ៣៦០ ] លំដាប់នោះ ព្រះមានព្រះភាគទ្រង់សម្តែងអនុ-បុព្វីកថា ដល់អនាថបិណ្ឌិកគហបតី ។ អនុបុព្វីកថានោះ គឺអ្វីខ្លះ ។

អនុបុព្វីកថានោះ គឺទ្រង់ប្រកាសនូវទានកថា ១ សីលកថា ១ សគ្គកថា ១ កាមាទីនវៈដ៏លាមកសៅហ្មង ១ និងអានិសង្ស ក្នុងការចេញកសាងផ្នួស ១ ។ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ ថា អនាថបិណ្ឌិកគហបតីមានចិត្តស្រួល មានចិត្តទន់ មានចិត្ត ប្រាសចាកនីវរណធម៌ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា ក្នុង ពេលណា ក៏ធម្មទេសនាដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើង សម្តែងដោយព្រះអង្គឯង ព្រះអង្គទ្រង់ប្រកាសនូវធម្មទេសនានោះ គឺទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ក្នុងពេលនោះ ។ សំពត់ដ៏ស្អាតដែលមិនមានពណ៌ខ្មៅ តែងទទួលយកនូវទឹក ជ្រលក់ដោយប្រពៃយ៉ាងណាមិញ ក៏ដូចជាធម្មចក្ខុ គឺសោតា-បត្តិផល មានធូលីទៅប្រាសហើយ មានមន្ទិលទៅប្រាសហើយ ក៏បានកើតឡើងដល់អនាថបិណ្ឌិកគហបតី លើអាសនៈនោះ ដូច្នេះថា ធម្មជាតឯណានីមួយ មានសភាពកើតឡើងហើយ ជាធម្មតា ធម្មជាតទាំងអស់នោះ មានសភាពរលត់ទៅវិញ ជាធម្មតា ។

# គាថាធម្មបទ នៅក្នុងសហស្សវគ្គ
## ( បិដក ៥២ ទំព័រ ៤៥ )

យោ ច វស្សសតំ ជីវេ
ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ
សីលវន្តស្ស ឈាយិនោ ។

*បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានសីល មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។*

## អដ្ឋកថា

*បណ្ដាបទទាំងនោះ បទថា ទុស្សីលោ ប្រែថា មិនមានសីល ។*

*បទថា សីលវន្តស្ស សេចក្ដីថា ការរស់នៅ សូម្បីតែមួយថ្ងៃ គឺសូម្បីតែមួយភ្លែតរបស់អ្នកមានសីល មានឈាន ដោយឈាន ២ ប្រការ ប្រសើរជាង គឺខ្ពង់ខ្ពស់ជាងការរស់នៅ ១០០ ឆ្នាំ របស់អ្នកទ្រុស្តសីល ។*

យោ ច វស្សសតំ ជីវេ
ទុប្បញ្ញោ អសមាហិតោ

ឯកាហំ ជីវិតំ សេយ្យោ

បញ្ញវន្តស្ស ឈាយោនោ ។

*បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានប្រាជ្ញា មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។*

## អដ្ឋកថា

*បណ្ដាបទទាំងនោះ បទថា ទុប្បញ្ញោ សេចក្ដីថា អ្នកគ្មានបញ្ញា ។*

*បទថា បញ្ញវន្តស្ស សេចក្ដីថា អ្នកមានបញ្ញា ។*

## បុញ្ញកិរិយាវត្ថុ
## ( អភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ទំព័រ ១៦៥ )

**១. ទានមយៈ** *បុណ្យសម្រេចពីការធ្វើទាន គឺការលះបង់ទ្រព្យ ឲ្យជាប្រយោជន៍ដល់អ្នកដទៃ*

**២. សីលមយៈ** *បុណ្យសម្រេចពីការរក្សាសីល គឺវៀរទុច្ចរិតកម្ម*

៣. **ភាវនាមយៈ** បុណ្យសម្រេចពីការចម្រើនសមថៈ និង វិបស្សនា

៤. **អបចាយនមយៈ** បុណ្យសម្រេចពីការគោរពឱន លំទោន ដល់អ្នកដទៃ ដែលគួរគោរពឱនលំទោន

៥. **វេយ្យាវច្ចមយៈ** បុណ្យសម្រេចពីការជួយធ្វើកិច្ចការ នៃបុណ្យ

៦. **បត្តិទានមយៈ** បុណ្យសម្រេចពីការឧទ្ទិសចំណែក បុណ្យ ឲ្យអ្នកដទៃ

៧. **បត្តានុមោទនាមយៈ** បុណ្យសម្រេចពីការអនុមោទនា

៨. **ទេសនាមយៈ** បុណ្យសម្រេចពីការសម្តែងធម៌

៩. **ធម្មស្សវនមយៈ** បុណ្យសម្រេចពីការស្តាប់ធម៌

១០. **ទិដ្ឋុជុកម្ម** ដោយការធ្វើទិដ្ឋិឲ្យត្រឹមត្រូវល្អ ។

ជំនឿកម្ម ជំនួញត្រូវ ( ដោយឧបាសក ធឹង កាន )

# មាតាបិតុគុណសូត្រ
# បិដកលេខ ៤០ ទំព័រ ១៣៧

[ ២៧៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា កុលបុត្ត មិនងាយនឹងធ្វើការតបគុណដល់បុគ្គលពីរពួកបានទេ ។ បុគ្គលពីរពួក តើនរណាខ្លះ ។ គឺមាតា ១ បិតា ១ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តមានអាយុ ១០០ ឆ្នាំ រស់នៅអស់រវាង ១០០ ឆ្នាំ គប្បីបញ្ជិះមាតាដោយស្មាម្ខាង បញ្ជិះបិតាដោយស្មាម្ខាង កុលបុត្តនោះបម្រើមាតាបិតាទាំងពីរនោះ ដោយការជុសជម្រះបំបាត់ក្លិនអាក្រក់ រិតនួតដៃផ្ងូតទឹកគក់ប្របាច់ដៃជើង ឯមាតាបិតាទាំងពីរនោះក៏បន្ទោបង់មូត្រករីសលើស្មាកុលបុត្រនោះឯង ម្នាលភិក្ខុទាំងឡាយ ( ហេតុមានប្រមាណប៉ុណ្ណេះ ) គង់មិនទាន់ហៅថាធ្វើ ឬថាធ្វើតបដល់មាតា និងបិតាឡើយ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រតម្កើងមាតា និងបិតាឲ្យតាំងនៅក្នុងរាជសម្បត្តិ មានឥស្សរភាពជាអធិបតី លើផែនដីធំ ដែលមានកែវទាំង ៧ ប្រការច្រើននេះ ម្នាលភិក្ខុទាំងឡាយ ( ហេតុមានប្រមាណប៉ុណ្ណេះ ) គង់មិនទាន់ហៅថា ធ្វើ ឬថាធ្វើតបដល់មាតា និងបិតាឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះមាតា និងបិតា មានឧបការៈច្រើនដល់បុត្រទាំងឡាយ ( បើ ) កុលបុត្តណាមួយ ដឹកនាំមាតា និងបិតា ដែលមិនមានសទ្ធា

*ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងសទ្ធាសម្បទា បើទ្រុស្តសីល ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងសីល-សម្បទា បើកំណាញ់ ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងចាគសម្បទា បើឥតបញ្ញា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងបញ្ញាសម្បទា ម្នាលភិក្ខុទាំងឡាយ ហេតុមានប្រមាណប៉ុណ្ណេះ ទើបហៅថា ធ្វើ ឬថាធ្វើតបដល់មាតា និងបិតាមែន ។*

*ម្នាលភិក្ខុទាំងឡាយ បើពួកសត្វដឹងផលនៃការចែកទានដូចជាតថាគតដឹងដូច្នោះ បើមិនទាន់ឲ្យទានទេ ក៏មិនហ៊ានបរិភោគឡើយ ។* ( **សុត្តន្តបិដក ៥៣ ទំព័រ ២៥** )

បុញ្ញញ្ចេ បុរិសោ កយិរា  កយិរា នំ បុនប្បុនំ
តម្ហិ ឆន្ទំ កយិរាថ  សុខោ បុញ្ញស្ស ឧច្ចយោ។

*បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឲ្យរឿយ ៗ គួរធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះ ( ព្រោះថា ) ការសន្សំបុណ្យ តែងនាំសេចក្តីសុខមកឲ្យ ។* ( **សុត្តន្តបិដក ៥២ ទំព័រ ៤៧** )

# មេត្តាចេតោវិមុត្តិ
# បិដកលេខ ៥១ ទំព័រ ២៩៧

*អានិសង្ស ១១ ប្រការ គឺរមែងដេកលក់ស្រួល ១ ភ្ញាក់ឡើងស្រួល ១ មិនឃើញនូវសុបិនអាក្រក់ ១ ជាទីស្រឡាញ់របស់ពួកមនុស្ស ១ ជាទីស្រឡាញ់របស់ពួកអមនុស្ស ១ ពួកទេវតាតែងរក្សា ១ ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី មិនចូលទៅក្នុងកាយ ១ ចិត្តរមែងតាំងនៅមាំធាប់ ១ សម្បុរមុខថ្លាស្រស់បស់ ១ ជាអ្នកមិនវង្វេងហើយធ្វើមរណកាល ១ កាលបើមិនទាន់ត្រាស់ដឹងនូវអរហត្តដ៏ក្រៃលែងជាងមេត្តាសមាបត្តិទេ រមែងបានទៅកើតក្នុងព្រហ្មលោក ។*

សព្វទានំ ធម្មទានំ ជិនាតិ
សព្វរសំ ធម្មរសោ ជិនាតិ
សព្វរតឹ ធម្មរតិ ជិនាតិ
តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។

*ធម្មទាន ឈ្នះអាមិសទានទាំងពួង ធម្មរស ឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ ឈ្នះសេចក្តីត្រេកអរទាំងពួង ការអស់តណ្ហា ឈ្នះទុក្ខទាំងពួង ។* ( **សុត្តន្តបិដក ៥២ ទំព័រ ៩៦** )